## ទាក់ទងយើងខ្ញុំ

**លេខទូរសព្ទ**
206-296-VOTE (8683)
1-800-325-6165
បញ្ជូនសារបន្តតាមទូរអង្គុលីលេខ៖ 711

**អ៊ីមែល**
elections@kingcounty.gov

**គេហទំព័រ**
kingcounty.gov/elections

**តាមសំបុត្រ ឬមានវត្តមានផ្ទាល់**
ទីស្នាក់ការកណ្តាលរៀបចំការបោះឆ្នោត
919 Southwest Grady Way
Renton, WA 98057

បើកនៅថ្ងៃធ្វើការពីម៉ោង
8:30 ព្រឹក – 4:30 រសៀល

### ទាក់ទងយើងខ្ញុំតាមបណ្តាញសង្គម

twitter.com/kcelections
facebook.com/kcelections
instagram.com/kcelections



### ជំនួយសម្រាប់ជនពិការក្នុងការបោះឆ្នោត

មណ្ឌលបោះឆ្នោតនានាមានឧបករណ៍ជំនួយសម្រាប់បុគ្គលដែលកំពុងមានបញ្ហាពិបាកក្នុងការបំពេញសន្លឹកឆ្នោតតាមសំបុត្ររបស់ខ្លួន។ ប្រសិនបើអ្នកកំពុងមានបញ្ហាពិបាកក្នុងការបោះឆ្នោត សូមទាក់ទងយើងខ្ញុំតាមរយៈលេខ 206-296-VOTE (8683)

### ខ្លឹមសារបោះឆ្នោតជាភាសាផ្សេងទៀត

បន្ថែមលើភាសាអង់គ្លេស King County Elections ផ្តល់ជូនសន្លឹកឆ្នោត និងខ្លឹមសារបោះឆ្នោតទាំងអស់ជាភាសាចិន កូរ៉េ អេស្ប៉ាញ និងវៀតណាម។

សូមទាក់ទងយើងខ្ញុំ ដើម្បីស្នើសុំខ្លឹមសារបោះឆ្នោតជាភាសាមួយក្នុងចំណោមភាសាទាំងនេះ។

vote!

# ការណែនាំអំពី
# ការបោះឆ្នោតនៅ King County

King County
Elections








## អ្នកដែលអាចចុះឈ្មោះបោះឆ្នោតបាន

អ្នកត្រូវតែជាពលរដ្ឋ និវាសនជនស្របច្បាប់នៃរដ្ឋវ៉ាស៊ីនតោន មានអាយុយ៉ាងតិចដប់ប្រាំមួយឆ្នាំ មិនត្រូវបានដកសិទ្ធិបោះឆ្នោតដោយដីកាបង្គាប់ពីតុលាការ និងបច្ចុប្បន្នមិនជាប់ពន្ធនាគារដោយការផ្តន្ទាទោសពីបទឧក្រិដ្ឋ។

បុគ្គលអាយុ 16 និង 17 ឆ្នាំអាចចុះឈ្មោះបោះឆ្នោតជាមុនបាន ហើយនឹងចាប់ផ្តើមទទួលបានសន្លឹកឆ្នោតរបស់ខ្លួនដោយស្វ័យប្រវត្តិ នៅពេលពួកគេមានសិទ្ធិបោះឆ្នោត។

NEW

ចាប់ពីខែមករា ឆ្នាំ 2022 សិទ្ធិបោះឆ្នោតត្រូវបានស្តារឡើងវិញភ្លាមៗ នៅពេលដោះលែងក្រោយការផ្តន្ទាទោសពីបទឧក្រិដ្ឋ ដោយមិនគិតពីស្ថានភាពក្រោមការឃ្លាំមើលក្នុងសហគមន៍។ បុគ្គលដែលត្រូវបានផ្តន្ទាទោសជាមុនគ្រាន់តែចុះឈ្មោះបោះឆ្នោត បន្ទាប់ពីដោះលែងជាការស្រេច។

NEW

បុគ្គលអាយុ 17 ឆ្នាំដែលនឹងគ្រប់អាយុ 18 ឆ្នាំមុនការបោះឆ្នោតសកលអាចបោះឆ្នោតនៅក្នុងការបោះឆ្នោតបឋមបាន។ ប្រសិនបើត្រូវបានចុះឈ្មោះបោះឆ្នោតជាមុន បុគ្គលអាយុ 17 ឆ្នាំដែលមានសិទ្ធិនឹងទទួលបានសន្លឹកឆ្នោតរបស់ខ្លួនដោយស្វ័យប្រវត្តិសម្រាប់ការបោះឆ្នោតលើកទីមួយដែលពួកគេមានសិទ្ធិបោះឆ្នោត។

## ទទួលបានសន្លឹកឆ្នោតរបស់អ្នក

បន្ទាប់ពីអ្នកត្រូវបានចុះឈ្មោះបោះឆ្នោត យើងនឹងផ្ញើសន្លឹកឆ្នោតរបស់អ្នកទៅអាសយដ្ឋានផ្ញើសំបុត្ររបស់អ្នកនៅមុនការបោះឆ្នោតបន្ទាប់ប្រហែលបីសប្តាហ៍ ដែលលឿនជាងសម្រាប់សេវា និងអ្នកបោះឆ្នោតនៅក្រៅប្រទេស។

## ស្វែងយល់អំពីខ្លឹមសារលើសន្លឹកឆ្នោតរបស់អ្នក

មុនការបោះឆ្នោតនីមួយៗ អ្នកក៏នឹងទទួលបានសៀវភៅព័ត៌មានសម្រាប់អ្នកបោះឆ្នោត ដែលរួមបញ្ចូលសេចក្តីថ្លែងការណ៍ និងព័ត៌មានទំនាក់ទំនងសម្រាប់បេក្ខជន ក៏ដូចជាព័ត៌មានបន្ថែមអំពីវិធានការលើសន្លឹកឆ្នោតផងដែរ។

អ្នកក៏អាចស្វែងរកការណែនាំដែលសម្របតាមអ្នកបោះឆ្នោត ដែលនឹងបង្ហាញតែការប្រកួតប្រជែងដែលអ្នកមានសិទ្ធិបោះឆ្នោតតែប៉ុណ្ណោះនៅគេហទំព័រ kingcounty.gov/elections/my-voter-information។

kingcounty.gov/elections

## បោះឆ្នោតលើសន្លឹកឆ្នោតរបស់អ្នក

ប្រើប៊ិចពណ៌ណាក៏បានដើម្បីបំពេញក្នុងរង្វង់រាងពងក្រពើដែលនៅជាប់នឹងជម្រើសរបស់អ្នកក្នុងការប្រកួតប្រជែងនីមួយៗ។ ប្រសិនបើបំពេញខុស អ្នកគ្រាន់តែឆូតចោលជម្រើសទាំងមូល រួមទាំងរង្វង់រាងពងក្រពើ រួចបំពេញរង្វង់រាងពងក្រពើដែលនៅជាប់នឹងជម្រើសថ្មីរបស់អ្នកជាការស្រេច។ យើងលើកទឹកចិត្តឱ្យអ្នកបោះឆ្នោតលើសន្លឹកឆ្នោតទាំងមូលរបស់អ្នក ប៉ុន្តែអ្នកអាចរំលងការប្រកួតប្រជែងណាក៏បានតាមចិត្ត ហើយយើងនឹងរាប់តែការប្រកួតប្រជែងដែលអ្នកបានបោះឆ្នោតប៉ុណ្ណោះ។

## ចុះហត្ថលេខាលើស្រោមសំបុត្រត្រឡប់មកវិញរបស់អ្នក

ដើម្បីអាចឱ្យគេរាប់សន្លឹកឆ្នោតរបស់អ្នកបាន អ្នកត្រូវតែចុះហត្ថលេខាលើសេចក្តីប្រកាសនៅលើស្រោមសំបុត្រត្រឡប់មកវិញ ហើយហត្ថលេខានោះត្រូវតែដូចគ្នាទៅនឹងហត្ថលេខានៅលើកំណត់ត្រាចុះបញ្ជីអ្នកបោះឆ្នោតរបស់អ្នក។ ហត្ថលេខារបស់អ្នកមិនចាំបាច់សរសេរជាអក្សរជាប់គ្នា ឬសរសេរឱ្យអានយល់នោះទេ ពោលគឺគ្រាន់តែដូចគ្នាទៅនឹងហត្ថលេខានៅលើឯកសារជាការស្រេច។ ប្រសិនបើហត្ថលេខារបស់អ្នកមិនដូចគ្នា ឬមិនបានចុះហត្ថលេខា យើងនឹងផ្ញើសំបុត្រមួយច្បាប់ទៅអ្នក រួចទាក់ទងតាមទូរសព្ទនិងអ៊ីមែល ប្រសិនបើយើងមានព័ត៌មាននោះនៅលើឯកសារ។ យើងគ្រាន់តែត្រូវការឱ្យអ្នកបំពេញ រួចផ្ញើទម្រង់បែបបទដ៏សាមញ្ញមកវិញប៉ុណ្ណោះ។

## ផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញ

អ្នកអាចផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញតាមសំបុត្រ ដាក់នៅ Vote Center (មណ្ឌលបោះឆ្នោត) ឬ Student Engagement Hub (មជ្ឈមណ្ឌលភ្ជាប់ទំនាក់ទំនងនិស្សិត) ឬដាក់ក្នុងធុងទម្លាក់សន្លឹកឆ្នោតសុវត្ថិភាពជាង 70 កន្លែងដែលស្ថិតនៅទូទាំង King County ដោយមិនបាច់បិទតែមនោះទេ។

ប្រសិនបើអ្នកជ្រើសរើសផ្ញើសន្លឹកឆ្នោតរបស់អ្នកតាមសំបុត្រ យើងសូមណែនាំឱ្យផ្ញើត្រឹមថ្ងៃសុក្រមុនថ្ងៃបោះឆ្នោត ដើម្បីឱ្យប្រាកដថាអាចវាយត្រាប្រៃសណីយ៍ទាន់ពេល។ ដើម្បីឱ្យគេរាប់បាន សន្លឹកឆ្នោតរបស់អ្នកត្រូវតែវាយត្រាប្រៃសណីយ៍នៅត្រឹមថ្ងៃបោះឆ្នោត ឬដាក់ក្នុងធុងទម្លាក់សន្លឹកឆ្នោតត្រឹមម៉ោង 8 យប់គត់។

## តាមដានសន្លឹកឆ្នោតរបស់អ្នក

សូមពិនិត្យមើលប្រព័ន្ធតាមដានសន្លឹកឆ្នោតលើអ៊ីនធឺណិត ដើម្បីឱ្យប្រាកដថាសន្លឹកឆ្នោតរបស់អ្នកត្រូវបានទទួល និងត្រូវបានគេរាប់។ ប្រព័ន្ធតាមដានសន្លឹកឆ្នោតលើអ៊ីនធឺណិតក៏ជាវិធីរហ័សបំផុតផងដែរ ដើម្បីឱ្យដឹងថាសន្លឹកឆ្នោតរបស់អ្នកមានបញ្ហាហត្ថលេខាឬអត់ ដើម្បីឱ្យអ្នកអាចដោះស្រាយបញ្ហានេះ និងឱ្យគេរាប់សន្លឹកឆ្នោតរបស់អ្នកបាន។ តាមដានសន្លឹកឆ្នោតរបស់អ្នកនៅគេហទំព័រ kingcounty.gov/elections/ballot-tracker។